ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ: ១៩៤០ សជណ

## សេចក្តីជូនដំណឹង
## ស្តីពីសេវាបន្ថែមលើការផ្តល់លិខិតឆ្លងដែន

ដើម្បីបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាឱ្យកាន់តែល្អជូនប្រជាពលរដ្ឋ ស្របតាមយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល **ក្រសួងមហាផ្ទៃ** មានកិត្តិយសសូមជូនដំណឹងដល់សាធារណជន អំពីសេវាបន្ថែមលើការផ្តល់លិខិតឆ្លងដែនដូចខាងក្រោម៖

១. ដើម្បីកាត់បន្ថយពេលវេលារង់ចាំរបស់ប្រជាពលរដ្ឋនៅទីតាំងផ្តល់លិខិតឆ្លងដែន **អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម** នឹងដាក់ឱ្យប្រើប្រាស់សាកល្បងនូវសេវាផ្តល់លិខិតឆ្លងដែន តាមប្រព័ន្ធអនឡាញ (Online) ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ ដោយបងប្អូនប្រជាពលរដ្ឋអាចចូលទៅកាន់គេហទំព័រ **សេវាអត្តសញ្ញាណកម្ម** ឬស្កេន QR Code ខាងក្រោមដើម្បីបំពេញបែបបទ៖

https://online.gdi.gov.kh/login

ក្រោយបំពេញបែបបទតាមប្រព័ន្ធអនឡាញរួច សាមីខ្លួនត្រូវអញ្ជើញទៅកាន់ទីស្នាក់ការ ឬសាខាលិខិតឆ្លងដែនណាមួយតាមការកំណត់ ដើម្បីសម្ភាស ថតរូប ផ្តិតខ្ទៅដៃ និងបង់សេវារដ្ឋបាល ដោយភ្ជាប់ជាមួយនូវពាក្យស្នើសុំ (តាមប្រព័ន្ធខាងលើ) និងឯកសារយោង។

២. ចំពោះប្រជាពលរដ្ឋមានជំងឺធ្ងន់ ឬចាស់ជរា ឬពិការភាព ដែលពុំអាចធ្វើដំណើរទៅកាន់ទីតាំងផ្តល់សេវាដោយផ្ទាល់បាន សមាជិកគ្រួសារ ឬតំណាងអាចដាក់ពាក្យស្នើសុំទៅកាន់ **អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម** ដោយភ្ជាប់ជាមួយនូវសំបុត្របញ្ជាក់ពីពេទ្យ ឬរូបថតអំពីស្ថានភាពនៃអ្នកជំងឺ ឬស្ថានភាពអ្នកស្នើសុំ។ គំរូពាក្យស្នើសុំផ្តល់សេវាលិខិតឆ្លងដែនក្រៅទីតាំងផ្លូវការ មានភ្ជាប់ជូនក្នុងឧបសម្ព័ន្ធ។ **អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម** នឹងពិនិត្យចាត់ក្រុមការងារ ចុះផ្តល់សេវាដល់ទីតាំងរបស់សាមីខ្លួនដោយពុំគិតកម្រៃសេវាបន្ថែម សម្រាប់ទីតាំងនៅក្នុងរាជធានីភ្នំពេញ។

៣. សម្រាប់បងប្អូនប្រជាពលរដ្ឋ ដែលមានការងារមមាញឹកខ្លាំងនៅថ្ងៃធ្វើការ អាចអញ្ជើញទៅកាន់ទីស្នាក់ការផ្តល់លិខិតឆ្លងដែននៅ **ផ្សារទំនើបអ៊ីអន២ សែនសុខ** នៅថ្ងៃចុងសប្តាហ៍ (ថ្ងៃសៅរ៍ និងថ្ងៃអាទិត្យ) ដើម្បីទទួលសេវា។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងទៅកាន់លេខទូរស័ព្ទប្រចាំការសេវាអត្តសញ្ញាណកម្ម **"១២៧១"** រៀងរាល់ម៉ោងធ្វើការ (លើកលែងថ្ងៃឈប់សម្រាក)។ អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជនមេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃ....................ខែ..........ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ២០២៤

ឯកសារភ្ជាប់៖
- ឧបសម្ព័ន្ធ. ពាក្យស្នើសុំផ្តល់សេវាលិខិតឆ្លងដែនក្រៅទីតាំងផ្លូវការ

ទីស្តីការក្រសួងមហាផ្ទៃ លេខ ២៧៥ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣៧២៦០៥២-២៣៧២៦០៥៣
ទូរសារ (៨៥៥) ២៣៧២៦០៥២-២៣៧២៦០៥៣ e-mail: moi@interior.gov.kh web: www.interior.gov.kh

ឧបសម្ព័ន្ធ.

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## ពាក្យស្នើសុំផ្តល់សេវាលិខិតឆ្លងដែន ក្រៅទីតាំងផ្លូវការ

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ................................ ភេទ.......... កើតថ្ងៃទី...... ខែ........... ឆ្នាំ...........
ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ............. ផ្លូវ.................... ភូមិ........................ ឃុំ/សង្កាត់.....................
ក្រុង/ស្រុក/ខណ្ឌ ...................... រាជធានី/ខេត្ត....................... ទូរស័ព្ទទំនាក់ទំនង.........................
កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ.......................... មុខរបរបច្ចុប្បន្ន..................................

## សូមគោរពជូន
## ឯកឧត្តម អគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម

**តាមរយៈ៖** លោកប្រធាននាយកដ្ឋានលិខិតឆ្លងដែន

**កម្មវត្ថុ ៖** សំណើសុំក្រុមការងារចល័តរបស់អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ចុះផ្តល់សេវាលិខិតឆ្លងដែន
ជូនឈ្មោះ..................................... ភេទ.......... កើតថ្ងៃទី...... ខែ........... ឆ្នាំ..........
កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ................................ ត្រូវជា.........................
ផ្តល់នៅទីតាំង ផ្ទះ/អគារលេខ.................................. ផ្លូវ.......... សង្កាត់.....................
ខណ្ឌ .......................... រាជធានីភ្នំពេញ។

**មូលហេតុ៖** ឈ្មោះខាងលើ ពុំអាចធ្វើដំណើរទៅកាន់ទីតាំងផ្តល់សេវាដោយផ្ទាល់បាន ដោយមូលហេតុ៖

❑ ចាស់ជរា ❑ មានជំងឺធ្ងន់
❑ ពិការភាព ❑ ផ្សេងទៀត............................................... ។

អាស្រ័យដូចបានគោរពជូនខាងលើ សូម **ឯកឧត្តម អគ្គនាយក** នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម មេត្តាពិនិត្យ និងសម្រេចដោយអនុគ្រោះ។

**ឯកសារភ្ជាប់៖* *១.ឯកសារសម្គាល់ ឬរូបថត បញ្ជាក់អំពីស្ថានភាពដែលពុំអាចធ្វើដំណើរមកស្នើសុំសេវា និង*
*២.សេចក្តីចម្លងសំបុត្រកំណើត ឬអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរអ្នកទទួលសេវា (សាមីខ្លួន)។*

សូម **ឯកឧត្តម** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

ថ្ងៃ...................... ខែ........... ឆ្នាំ.................... ព.ស.............

លេខ......................

រាជធានីភ្នំពេញ ថ្ងៃទី........... ខែ.......... ឆ្នាំ..............

**ស្នាមមេដៃស្តាំ**

**សូមគោរពជូន**

**ឯកឧត្តម អគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម**

"មេត្តាពិនិត្យ និងសម្រេចដ៏ខ្ពង់ខ្ពស់"

រាជធានីភ្នំពេញ ថ្ងៃទី........... ខែ......... ឆ្នាំ.........

**ប្រធាននាយកដ្ឋានលិខិតឆ្លងដែន**